# ប្រកាសស្តីពីនីតិវិធី និងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីជីកសិកម្ម

## តមកពីទស្សនាវដ្តីកសិកម្មលេខ ៤៣

- ប្រភេទជីជីវសាស្ត្រមានបរិមាណយ៉ាងតិច២០០ក្រាម ឬ២០០ មិល្លីម៉ែត្រ។

២.២- វិធីសាស្ត្រវិភាគសមាសធាតុជីកសិកម្ម

២.៣- ទិន្នន័យវិភាគភ្នាក់ងារចម្លងជំងឺ

២.៤- ទិន្នន័យវិភាគសារធាតុលោហៈធ្ងន់

២.៥- ទិន្នន័យសាកល្បងស្មៅចង្រៃនិងសត្វល្អិតចង្រៃ។

៣ - ស្លាកសញ្ញាព័ត៌មាន

៣.១- សម្រាប់ជីទឹក

៣.២- សម្រាប់ជីគោក។

៤ - ព្រឹត្តិបត្របច្ចេកទេសស្តីពីផលិតផលចេញពីប្រភពដើមផលិតឬលាយផ្សំ។

៥ - ទិន្នន័យជីវប្រសិទ្ធភាពចេញពីប្រភពដើមផលិតឬលាយផ្សំ។

៦ - លទ្ធផលសាកល្បងលើទីវាលអនុវត្តដោយស្ថានីយពិសោធន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬអនុវត្តដោយអ្នកស្រាវជ្រាវដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៧ - របាយការណ៍ពិនិត្យវាយតម្លៃទីតាំងនិងដំណើរការលាយផ្សំ (សម្រាប់ផលិតកម្មក្នុងស្រុក)។

**ប្រការ ៦.-**

ការតម្រូវទូទៅសម្រាប់ការចុះបញ្ជីជីកសិកម្មដូចមានចែងក្នុងប្រការ៥នៃប្រកាសនេះ ត្រូវអនុវត្តតាមក្រុមប្រភេទជីកសិកម្មដូចខាងក្រោម៖

១- **ក្រុមជីអសរីរាង្គ** មិនតម្រូវទិន្នន័យវិភាគភ្នាក់ងារចម្លងជំងឺ និងមិនតម្រូវទិន្នន័យសាកល្បងស្មៅចង្រៃនិងសត្វល្អិតចង្រៃឡើយ។ ដោយឡែកចំពោះជីអសរីរាង្គធម្មតាដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មិនតម្រូវបន្ថែមនូវទិន្នន័យជីវប្រសិទ្ធភាពពីប្រទេសប្រភពដើម មិនតម្រូវលទ្ធផលសាកល្បងលើទីវាលពិសោធន៍ ដែលអនុវត្តដោយស្ថានីយពិសោធន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬដោយអ្នកស្រាវជ្រាវដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមិនតម្រូវព្រឹត្តិបត្របច្ចេកទេសឡើយ។

២- **ក្រុមជីសរីរាង្គ** ត្រូវការគ្រប់ព័ត៌មាននិងទិន្នន័យតាមការតម្រូវទូទៅសម្រាប់ការចុះបញ្ជីជីកសិកម្ម។

៣- **ក្រុមជីជីវសាស្ត្រ** មិនតម្រូវទិន្នន័យវិភាគលោហៈធ្ងន់ និងទិន្នន័យសាកល្បងស្មៅចង្រៃនិងសត្វល្អិតចង្រៃឡើយ។

៤/៣៥

៤- ក្រុមជីកែលំអគុណភាពដី មិនតម្រូវទិន្នន័យវិភាគភ្ជាក់ងារចម្លងជំងឺ ទិន្នន័យវិភាគលោហៈធ្ងន់ និងទិន្នន័យសាកល្បងស្មៅចង្រៃនិងសត្វល្អិតចង្រៃ ប៉ុន្តែត្រូវការព័ត៌មានបន្ថែមចំពោះប្រភេទជីល្បាប់៖

- ភាគរយនៃទំហំគ្រាប់ល្បាប់
- អត្រានៃសមាសធាតុសកម្មៈ $CaCO_3$ និង $MgCO_3$
- តម្លៃណឺតកម្ម (អត្រា $CaCO_3$ សមមូល%)។

៥- ក្រុមជីវត្ថុធាតុដើម មិនតម្រូវទិន្នន័យសាកល្បងស្មៅចង្រៃនិងសត្វល្អិតចង្រៃ និងមិនតម្រូវព្រឹត្តិបត្របច្ចេកទេសឡើយ។

សេចក្ដីអះអាងព័ត៌មាននិងទិន្នន័យស្ដីពីជីកសិកម្មដែលស្នើសុំការចុះបញ្ជី ត្រូវបានកំណត់ក្នុងឧបសម្ពន្ធទី២នៃប្រកាសនេះ។

## ជំពូកទី ៣
## បរិមាណីយធានានិងយថាប្រភេទជីកសិកម្ម

### ប្រការ ៧.-

សមាសធាតុនៃជីកសិកម្ម ត្រូវមានភាពដូចគ្នាជាមួយបរិមាណីយធានាចេញពីប្រភពដើមផលិតឬលាយផ្សំ ដែលត្រូវបង្ហាញក្នុងស្លាកសញ្ញាព័ត៌មាននៅលើសំបកវេចខ្ចប់។

លំអៀងអប្បបរមាអនុគ្រោះចំពោះបរិមាណីយធានានៃជីកសិកម្ម ត្រូវបានកំណត់ដូចខាងក្រោម៖

- ជីអសរីរាង្គត្រូវបានកំណត់២%(ពីរភាគរយ)នៃអត្រាសារធាតុចិញ្ចឹមចម្បងនីមួយៗ (N.P.K) ដែលបានអះអាង
- ជីសរីរាង្គត្រូវបានកំណត់៥%(ប្រាំភាគរយ)នៃអត្រារបស់សារធាតុចិញ្ចឹមចម្បងនីមួយៗ (N.P.K)
- ជីចម្រុះមីក្រូធាតុ ត្រូវបានកំណត់អាស្រ័យដោយកម្រិតមីក្រូធាតុដូចខាងក្រោម៖

| | |
|---|---|
| ១០% | កម្រិតអនុគ្រោះ 0.១(ឯកតា) |
| ១១-២០ % | កម្រិតអនុគ្រោះ 0.២(ឯកតា) |
| ≥ ២០% | កម្រិតអនុគ្រោះ 0.៥(ឯកតា)។ |

### ប្រការ ៨.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីជីកសិកម្ម ត្រូវដាក់ជូននាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមួយពាក្យស្នើសុំការចុះបញ្ជី ការធ្វើវិភាគនិងការសាកល្បងជីវប្រសិទ្ធភាពជីកសិកម្ម នូវសំណាកគំរូចំនួន២សំណាកដែលដកយកចេញពីគំនរឬឡូត៍តែមួយ ដើម្បីបញ្ជូនធ្វើវិភាគផ្ទៀងផ្ទាត់បរិមាណីយដើមនៃសារធាតុចិញ្ចឹមឬសមាសធាតុដោយ

៥/៣៥

មន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ណាមួយដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ជីកសិកម្មគ្រប់ប្រភេទដែលត្រូវស្នើសុំការចុះបញ្ជី ត្រូវធ្វើវិភាគផ្ទៀងផ្ទាត់បរិមាណីយជានាលើគ្រប់សមាសធាតុរបស់ជីរួមមាន សារធាតុចិញ្ចឹមចម្បង(N.P.K) សារធាតុចិញ្ចឹមបន្ទាប់បន្សំ និងមីក្រូធាតុ ឬសារធាតុបំប៉នផ្សេងទៀត(Trace Elements"TE")ជាចាំបាច់។

**ប្រការ ៩.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីអាចទទួលព័ត៌មានស្តីពីលទ្ធផលវិភាគសំណាកជីកសិកម្ម នៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេលមិនលើសពី៤៥(សែសិបប្រាំ)ថ្ងៃគិតចាប់ពីថ្ងៃបានទទួលសំណាកជីកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំធ្វើវិភាគសំណាកជីកសិកម្ម ត្រូវទទួលបន្ទុកលើការបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម។

**ប្រការ ១០.-**

ជីកសិកម្មគ្រប់ប្រភេទដែលស្នើសុំការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវមានយថាប្រភេទដូចខាងក្រោម៖

ក- ក្រុមប្រភេទជីសរីរាង្គ

ខ- ក្រុមប្រភេទជីអសរីរាង្គ

១- យថាប្រភេទក្រុមជីអាហ្សូត "N" ។

២- យថាប្រភេទក្រុមជីហ្វូស្វាត "P" ។

៣- យថាប្រភេទក្រុមជីប៉ូតាស "K" ។

៤- យថាប្រភេទក្រុមជីចម្រុះ "N, P" ។

៥- យថាប្រភេទក្រុមជីចម្រុះ "P, K" ។

៦- យថាប្រភេទក្រុមជីចម្រុះ "N,P,K" ។

៧- យថាប្រភេទក្រុមជីមីក្រូធាតុ។

បរិមាណីយយថាប្រភេទនៃក្រុមជីសរីរាង្គ ត្រូវបានកំណត់ក្នុងឧបសម្ពន្ធទី៣នៃប្រកាសនេះ។

បញ្ជីជីកសិកម្មតាមក្រុមប្រភេទនិងយថាប្រភេទ ត្រូវកំណត់ដោយប្រកាសដោយឡែករបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

# ជំពូកទី ៤
# ទិន្នន័យជីវប្រសិទ្ធភាព

**ប្រការ ១១.-**

ទិន្នន័យជីវប្រសិទ្ធភាពគឺជាការតម្រូវបមាណីយចាំបាច់ដែលត្រូវផ្ដល់សម្រាប់ការចុះបញ្ជីយថាប្រភេទជីកសិកម្មណាមួយតាមរយៈការផ្ដល់ទិន្នន័យប្រសិទ្ធភាពរបស់សារធាតុចិញ្ចឹមសម្រាប់ប្រភេទដំណាំជាក់លាក់ និងទិន្នន័យសាកល្បងផ្សេងទៀតដែលពាក់ព័ន្ធនឹងភាពពុលនៃជីកសិកម្មនិងសុវត្ថិភាពចំពោះមនុស្ស សត្វ និងក្បេត្របរិស្ថាន ដែលឆ្លើយតបតាមព័ត៌មានដូចចែងនៅក្នុងស្លាកសញ្ញាព័ត៌មានចេញពីប្រភពដើមផលិតឬលាយផ្សំ និងដែលបានអះអាងដោយអ្នកស្នើសុំការចុះបញ្ជី។

ទិន្នន័យជីវប្រសិទ្ធភាពជីកសិកម្មអាចបង្កើតតាមរយៈការស្នើសុំសាកល្បងលើទីវាលពិសោធន៍ ដោយអនុលោមតាមពិធីសារសាកល្បងជីវប្រសិទ្ធភាពជីកសិកម្ម។ ការសាកល្បងដើម្បីបង្កើតទិន្នន័យជីវប្រសិទ្ធភាពរបស់ជីកសិកម្មត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

- រដូវសាកល្បង
- ចំនួនលើកក្នុងការសាកល្បង
- ប្រភេទឬក្រុមប្រភេទដំណាំត្រូវធ្វើការសាកល្បង
- ប្រភេទជីកសិកម្មត្រូវធ្វើការសាកល្បង
- ប្រភេទដី ទីតាំង ឬតំបន់ដាំដុះត្រូវធ្វើការសាកល្បង។

**ប្រការ ១២.-**

លើកលែងតែប្រភេទជីអសរីរាង្គធម្មតា រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីប្រភេទជីជីវសាស្ត្រ ជីអសរីរាង្គផ្សេងទៀត ជីសរីរាង្គ ជីកែលំអគុណភាពដី ឬជីកសិកម្មទាំងឡាយណាដែលមានព័ត៌មានមិនគ្រប់គ្រាន់ពាក់ព័ន្ធបមាណីយជានា ប្រសិទ្ធភាពនៃសារធាតុចិញ្ចឹមនិងសុវត្ថិភាព តម្រូវឲ្យធ្វើការសាកល្បងជីវប្រសិទ្ធភាពដើម្បីបង្កើតទិន្នន័យជីវប្រសិទ្ធភាពសម្រាប់ការចុះបញ្ជី ដោយអនុលោមតាមពិធីសារសាកល្បងជីវប្រសិទ្ធភាពនៃជីកសិកម្ម និងនីតិវិធីនៃប្រកាសនេះ។

ប្រភេទជីអសរីរាង្គធម្មតាត្រូវបានរាប់បញ្ចូលនូវប្រភេទនៃជីអសរីរាង្គទាំងឡាយដែលមានសមាសធាតុជាយថាប្រភេទនៃក្រុមជីទោល អាហ្សូត(N) ហ្វូស្វាត(P) ប៉ូតាស(K) ក្រុមជីចម្រុះទ្វេធាតុ (N,P ឬ P,K) និងក្រុមជីចម្រុះត្រីធាតុ(N,K,P) និងមិនរាប់បញ្ចូលនូវជីអសរីរាង្គទាំងឡាយដែលមានការលាយផ្សំបន្ថែមនូវសារធាតុចិញ្ចឹមបន្ទាប់បន្សំ មីក្រូសារធាតុ ឬសារធាតុបំប៉នផ្សេងទៀត(TE) ឡើយ។

ប្រភេទជីអសរីរាង្គធម្មតា ត្រូវបានកំណត់ក្នុងឧបសម្ពន្ធទី៤នៃប្រកាសនេះ។

៧/៣៥

**ប្រការ ១៣.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីជីកសិកម្ម អាចស្នើសុំធ្វើវិភាគនិងធ្វើការសាកល្បងជីវប្រសិទ្ធភាពជាមុន ដោយត្រូវដាក់ពាក្យស្នើសុំការចុះបញ្ជី ការធ្វើវិភាគ និងការសាកល្បងជីវប្រសិទ្ធភាពជីកសិកម្មនោះ នៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំធ្វើវិភាគឬធ្វើការសាកល្បងជីវប្រសិទ្ធភាពសំណាកជីកសិកម្មសម្រាប់ការចុះបញ្ជី ត្រូវស្នើសុំលិខិតអនុញ្ញាតនាំចូលសំណាកជីកសិកម្មនោះជាមុននៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ សំណាកជីកសិកម្មត្រូវបានអនុញ្ញាតឲ្យនាំចូលតាមបរិមាណសមស្របសម្រាប់តែបម្រើការធ្វើវិភាគ ការសាកល្បងជីវប្រសិទ្ធភាព និងការសិក្សាទិន្នន័យផ្សេងទៀតនៃជីកសិកម្មដែលពាក់ព័ន្ធសម្រាប់ការចុះបញ្ជី ដោយអនុលោមតាមពិធីសារសាកល្បងជីវប្រសិទ្ធភាពនៃជីកសិកម្ម។

**ប្រការ ១៤.-**

ការសាកល្បងជីវប្រសិទ្ធភាពជីកសិកម្មត្រូវអនុវត្តដោយស្ថានីយពិសោធន៍កសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬដោយអ្នកស្រាវជ្រាវកសិកម្មដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយអនុលោមតាមពិធីសារសាកល្បងជីវប្រសិទ្ធភាពនៃជីកសិកម្ម។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំធ្វើការសាកល្បងជីវប្រសិទ្ធភាព អាចទទួលព័ត៌មានស្តីពីលទ្ធផលសាកល្បងជីវប្រសិទ្ធភាពនៃជីកសិកម្មនោះ នៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងរយៈពេល១(មួយ)ខែទៅ១២(ដប់ពីរ)ខែឬលើស គិតចាប់ពីថ្ងៃទទួលសំណាកជីកសិកម្ម អាស្រ័យតាមលក្ខខណ្ឌនៃការសាកល្បង។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំធ្វើការសាកល្បងជីវប្រសិទ្ធភាពនៃជីកសិកម្ម ត្រូវទទួលបន្ទុកលើការបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិ ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

## ជំពូកទី ៥
## ការវេចខ្ចប់និងការគម្រូវស្លាកសញ្ញាព័ត៌មាន

**ប្រការ ១៥.-**

ជីកសិកម្មគ្រប់ប្រភេទដែលធ្វើការលាយផ្សំ នាំចូលនាំចេញ ផ្គត់ផ្គង់ចែកចាយ សន្និធិ និងដាក់តាំងលក់ ត្រូវវេចក្នុងសម្ភារវេចខ្ចប់ដែលផលិតដោយវត្ថុធាតុដែលមិនងាយរហែកធ្លុះធ្លាយ មានភាពជាប់មាំល្អ ធន់នឹងធាតុអាកាស ហើយដែលសម្រួលដល់ការដឹកជញ្ជូន សន្និធិ និងប្រើប្រាស់។

៨/៣៥

ប្រភេទជីទឹកត្រូវវេចខ្ចប់ដោយសម្ភារវេចខ្ចប់ដែលធានាមិនឲ្យមានការលេចជ្រាប ការសាយភាយ ការស្រកមាឌ ការប្រែប្រួលគុណភាព និងត្រូវមានលក្ខណៈងាយស្រួលក្នុងការបោះពុម្ព ឬបិទភ្ជាប់ស្លាកសញ្ញា។

ការវេចខ្ចប់ជាថ្មីនូវជីកសិកម្មគ្រប់ប្រភេទ ត្រូវធានាដូចគ្នានូវសំបកវេចខ្ចប់ដែលជាប់មាំល្អ បិទភ្ជិតយ៉ាងត្រឹមត្រូវ និងធន់ចំពោះការកាន់យួរ ការដឹកជញ្ជូន និងត្រូវរក្សាស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរសម្រាប់អ្នកប្រើប្រាស់។

**ប្រការ ១៦.-**

ស្លាកសញ្ញាព័ត៌មានគឺជាបទបញ្ញាតតិយុត្តដែលបោះពុម្ពនៅលើសំបកវេចខ្ចប់ឬកំណត់ក្នុងបរិយាយប័ណ្ណព័ត៌មាននៃផលិតផលជីកសិកម្មណាមួយនៅក្នុងប្រតិបត្តិការវេចខ្ចប់ឬវេចខ្ចប់ជាថ្មី ដើម្បីធានាចំពោះអ្នកលក់និងអ្នកទិញនូវប្រភេទជីកសិកម្មដែលធានាប្រសិទ្ធភាពនិងសុវត្ថិភាព។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីជីកសិកម្ម ត្រូវភ្ជាប់ជាមួយពាក្យស្នើសុំការចុះបញ្ជី ការធ្វើវិភាគ និងការសាកល្បងជីវប្រសិទ្ធភាពជីកសិកម្ម នូវគំរូស្លាកសញ្ញាព័ត៌មានជីកសិកម្ម ដើម្បីពិនិត្យវាយតម្លៃ ឬកែតម្រូវជាមុនដោយនាយកដ្ឋាននីតិកម្មកសិកម្ម។

គំរូស្លាកសញ្ញាព័ត៌មាននិងបរិយាយប័ណ្ណព័ត៌មានសម្រាប់ជីកសិកម្ម ត្រូវមានការយល់ព្រមជាមុនពីនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅក្នុងដំណើរការនៃការចុះបញ្ជី។

**ប្រការ ១៧.-**

បមាណីយរួមសម្រាប់ស្លាកសញ្ញាព័ត៌មានជីកសិកម្មមាន៖

១- គ្រប់ព័ត៌មាននៅលើស្លាកសញ្ញាត្រូវតែមានជាភាសាខ្មែរ អាចអានបាន ងាយយល់ និងមិនងាយលុប។

២- ស្លាកសញ្ញាព័ត៌មានត្រូវកំណត់នៅក្នុងវណ្ឌគែមពណ៌ស្វាយដែលមានកម្រាស់ពី០.៣០សង់ទីម៉ែត្រទៅ០.៦០សង់ទីម៉ែត្រ សម្រាប់សំបកវេចខ្ចប់ចំណុះ២៥០មិល្លីម៉ែត្រឬទម្ងន់៣០០ក្រាមទៅចំណុះ៤លីត្រឬទម្ងន់៥គីឡូក្រាមឡើងទៅ។

៣- សម្រាប់ផលិតផលដែលវេចខ្ចប់ក្នុងកេស ឡាំង ឬថង់ផ្លាស្ទិចដែលមានទម្ងន់ពី១គីឡូក្រាមឡើងទៅ ព័ត៌មានស្តីពីផលិតផលត្រូវបោះពុម្ពផ្ទាល់លើសំបកវេចខ្ចប់។ វណ្ឌគែមជុំវិញស្លាកសញ្ញាព័ត៌មាន ត្រូវបោះពុម្ពលើសំបកវេចខ្ចប់ដូចគ្នា។

៤- ចំពោះផលិតផលដែលច្រកក្នុងសំបកវេចខ្ចប់ចំណុះទាបជាង២៥០មិល្លីម៉ែត្រ ស្លាកសញ្ញាអាចបោះពុម្ពតែព័ត៌មានស្តីពីផលិតផលប៉ុណ្ណោះ។ ចំពោះបទណែនាំស្តីពីរបៀបប្រើប្រាស់ត្រូវបោះពុម្ពនៅក្នុងបរិយាយប័ណ្ណព័ត៌មានដោយឡែក។

៩/៣៥

**ប្រការ ១៨.-**

បមាណីយស្លាកសញ្ញាព័ត៌មានសម្រាប់ប្រភេទជីទឹកមានដូចខាងក្រោម៖

ក-ផ្នែកកណ្ដាលសំបកវេចខ្ចប់៖

- ឈ្មោះពាណិជ្ជកម្ម ប្រភេទជីកសិកម្ម និងពាណិជ្ជសញ្ញា
- សារធាតុចិញ្ចឹមចម្បង (N, P, K)
- សារធាតុសកម្មជីវសាស្ត្រ(ក្នុងករណីជីជីវសាស្ត្រ)
- សារធាតុចិញ្ចឹមបន្ទាប់បន្សំ និងមីក្រូជាតុ(បើសិនជាមាន)
- ទម្ងន់ឬចំណុះសុទ្ធសាធ
- កាលបរិច្ឆេទផលិតនិងកាលបរិច្ឆេទផុតកំណត់
- លេខបញ្ជិកាផ្ដល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ប្រទេសប្រភពដើមលាយផ្សំឬនាំចេញ
- ឈ្មោះនិងអាសយដ្ឋានរបស់ក្រុមហ៊ុនដើមផលិតឬលាយផ្សំ នាំចូល និងផ្គត់ផ្គង់ចែកចាយ។

ខ-ផ្នែកខាងស្ដាំសំបកវេចខ្ចប់៖

- ព័ត៌មានអំពីផលិតផល
- របៀបប្រើប្រាស់៖ ប្រភេទដំណាំ កម្រិតប្រើប្រាស់ វិធីសាស្ត្រ និងពេលវេលាប្រើប្រាស់
- ព័ត៌មានឬសេចក្ដីណែនាំផ្សេងទៀត។

គ-ផ្នែកខាងឆ្វេងសំបកវេចខ្ចប់

- សន្និធិនិងការបោះចោល
- ភាពលាយបានជាមួយជីឬសារធាតុផ្សេងទៀត
- ការជានា
- ការហាមឃាត់ "ត្រូវរក្សាឲ្យផុតពីដៃក្មេង"
- លេខឡូត៍។

**ប្រការ ១៩.-**

បមាណីយស្លាកសញ្ញាព័ត៌មានសម្រាប់ប្រភេទជីគោកដែលវេចខ្ចប់ក្នុងថង់ឬការ៉ុង មានដូចខាងក្រោម៖

ក-ផ្នែកខាងមុខ៖

- ឈ្មោះពាណិជ្ជកម្ម ប្រភេទជីកសិកម្ម និងពាណិជ្ជសញ្ញា
- សារធាតុចិញ្ចឹមចម្បង (N, P, K)
- សារធាតុសកម្មជីវសាស្ត្រ (ក្នុងករណីជីជីវសាស្ត្រ)
- សារធាតុចិញ្ចឹមបន្ទាប់បន្សំ និងមីក្រូជាតុ(បើសិនជាមាន)

១០/៣៥

- សំណើម
- លេខបញ្ជិកាផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សម្រាប់ជីសរីរាង្គ ត្រូវមានព័ត៌មានបន្ថែមដូចខាងក្រោម៖
  + កម្រិត pH
  + អត្រាសារជាតុសរីរាង្គ(OM %)
  + ផលធៀបកាបូន និងអាហ្សូត(C:N)
  + ប្រភពនិងប្រភេទវត្ថុធាតុដើម។

ខ-ផ្នែកខាងខ្នង៖

- របៀបប្រើប្រាស់៖ ប្រភេទដំណាំ កម្រិតប្រើប្រាស់ វិធីសាស្ត្រ និងពេលវេលាប្រើប្រាស់
- ឈ្មោះនិងអាសយដ្ឋានក្រុមហ៊ុនដើមផលិតឬលាយផ្សំ នាំចូល និងផ្គត់ផ្គង់ចែកចាយ
- លេខគំនរ
- កាលបរិច្ឆេទផលិតនិងកាលបរិច្ឆេទផុតកំណត់
- ទម្ងន់សុទ្ធសាជ(គីឡូក្រាម)។

គំរូស្លាកសញ្ញាព័ត៌មានជីកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ពន្ធទី៥នៃប្រកាសនេះ។

## ជំពូកទី ៦
## នីតិវិធីនិងដំណើរការនៃការចុះបញ្ជីជីកសិកម្ម

**ប្រការ ២០.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីជីកសិកម្ម ត្រូវបំពេញពាក្យស្នើសុំនិងសំណុំបែបបទនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សំណុំឯកសារ ទិន្នន័យ និងព័ត៌មានសម្រាប់ភ្ជាប់ជាមួយពាក្យស្នើសុំការចុះបញ្ជីជីកសិកម្ម ត្រូវរៀបចំលើក្រដាសទំហំA4(២១០x២៩៧មម) និងត្រូវចងក្រងក្នុងសឺមីក្រាស់ដាច់ដោយឡែក តាមយថាប្រភេទផលិតផលស្នើសុំចុះបញ្ជីនីមួយៗ ដែលក្នុងមួយកម្រងឯកសារមានមាតិកាតាមលំដាប់លំដោយដូចខាងក្រោម៖

១- នៅលើក្របក្រៅត្រូវមានបង្ហាញនូវអត្តសញ្ញាណរបស់អ្នកស្នើសុំការចុះបញ្ជី និងយថាប្រភេទជីកសិកម្មដែលត្រូវស្នើសុំការចុះបញ្ជី។

២- ឯកសារចុះបញ្ជីពាណិជ្ជកម្មនិងឯកសារពាក់ព័ន្ធអត្តសញ្ញាណរបស់អ្នកស្នើសុំ។

៣- សេចក្តីអះអាងព័ត៌មាននិងទិន្នន័យស្តីពីយថាប្រភេទជីកសិកម្មដែលស្នើសុំការចុះបញ្ជីដែលមានចំនួនមួយយថាប្រភេទជីកសិកម្មក្នុងមួយសម្រង់ព័ត៌មាន។

៤- វិញ្ញាបនបត្របញ្ជាក់បមាណីយជានាសមាសជាតុចេញពីប្រភពដើមលាយផ្សំ ឬនាំចូល។

៥- លទ្ធផលវិភាគសមាសធាតុចេញដោយមន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៦- ទិន្នន័យជីវប្រសិទ្ធភាពចេញពីប្រភពដើមផលិតឬលាយផ្សំ។

៧- លទ្ធផលសាកល្បងជីវប្រសិទ្ធភាពចេញដោយស្ថានីយពិសោធន៍កសិកម្ម ឬដោយអ្នកស្រាវជ្រាវដែលមានការទទួលស្គាល់។

៨- ទិន្នន័យសាកល្បងភ្នាក់ងារចម្លងជំងឺ។

៩- ទិន្នន័យសាកល្បងលោហៈធ្ងន់។

១០-ទិន្នន័យសាកល្បងស្មៅចង្រៃនិងសត្វល្អិតចង្រៃ។

១១-គំរូស្លាកសញ្ញាព័ត៌មាន។

១២-គំរូសំបកវេចខ្ចប់ ប្រភេទ ទំហំ។

១៣-ប្រភពនិងប្រភេទវត្ថុធាតុដើម។

១៤-ព្រឹត្តិបត្របច្ចេកទេសស្ដីពីផលិតផលចេញពីប្រភពដើម។

១៥-សេចក្ដីសង្ខេបទូទៅអំពីដំណើរការផលិត ឬការលាយផ្សំចេញពីប្រភពដើម។

១៦-របាយការណ៍ពិនិត្យវាយតម្លៃទីតាំងនិងដំណើរការលាយផ្សំ(សម្រាប់ផលិតកម្មក្នុងស្រុក)។

ពាក្យស្នើសុំការចុះបញ្ជី ការធ្វើវិភាគ និងការសាកល្បងជីវប្រសិទ្ធភាពជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី៦នៃប្រកាសនេះ។

## ប្រការ ២១.-

សំណុំឯកសារស្នើសុំការចុះបញ្ជីជីកសិកម្ម ត្រូវបានពិនិត្យដោយនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លើភាពគ្រប់គ្រាន់នៃសំណុំឯកសារ ដោយអនុលោមតាមប្រកាសនេះ។ សំណុំឯកសារនឹងត្រូវបង្វែរឲ្យអ្នកស្នើសុំវិញ ក្នុងករណីនាយកដ្ឋាននីតិកម្មកសិកម្មពិនិត្យឃើញថាឯកសារមិនគ្រប់គ្រាន់។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចលើកលែងការតម្រូវទិន្នន័យឬព័ត៌មានណាមួយនៃជីកសិកម្មដែលស្នើសុំការចុះបញ្ជី ក្នុងករណីអ្នកស្នើសុំមានឯកសារប្រភពដើមបង្ហាញនូវទិន្នន័យឬព័ត៌មានទាំងនោះ ដែលបានមកពីការពិសោធន៍ ការសាកល្បងក្រោមលក្ខខណ្ឌក្សេត្របរិស្ថានដូចគ្នា ឬប្រហាក់ប្រហែលជាមួយនឹងលក្ខខណ្ឌក្សេត្របរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា។

ការតម្រូវឯកសារស្ដីពីទិន្នន័យនិងព័ត៌មានសម្រាប់ការចុះបញ្ជីជីកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ពន្ធទី៧ នៃប្រកាសនេះ។

## ប្រការ ២២.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីជីកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិសម្រាប់ការចុះបញ្ជីតាមចំនួនយថាប្រភេទជីកសិកម្មដែលស្នើសុំការចុះបញ្ជី នៅពេលដែល

១២/៣៥

សំណុំឯកសារត្រូវបានទទួលយកដោយនាយកដ្ឋាននីតិកម្មកសិកម្ម ដើម្បីដាក់ឆ្លងដំណើរការពិនិត្យ និងវាយតម្លៃ។

**ប្រការ ២៣.-**

សំណុំឯកសារស្នើសុំការចុះបញ្ជីដីកសិកម្មដែលបំពេញគ្រប់គ្រាន់ និងភ្ជាប់ជាមួយប័ណ្ណចំណូលកម្រៃសេវាកម្មសម្រាប់ការចុះបញ្ជី ត្រូវបានបញ្ចូលក្នុងដំណើរការនៃការចុះបញ្ជីដើម្បីពិនិត្យនិងវាយតម្លៃលើការតម្រូវបមាណីយ។

នាយកដ្ឋាននីតិកម្មកសិកម្មត្រូវធ្វើសំយោគរបាយការណ៍វាយតម្លៃនិងត្រូវបញ្ជូនសំណុំឯកសារស្នើសុំការចុះបញ្ជី ដើម្បីស្នើសុំការពិនិត្យសម្រេចចុងក្រោយរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អ្នកស្នើសុំការចុះបញ្ជីដីកសិកម្ម អាចទទួលព័ត៌មានស្តីពីលទ្ធផលនៃការសម្រេចរបស់រដ្ឋមន្ត្រីនៅនាយកដ្ឋាននីតិកម្មកសិកម្មក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលយកសំណុំឯកសារគ្រប់គ្រាន់។

គំនូសបំព្រួញស្តីពីដំណើរការនៃការចុះបញ្ជីដីកសិកម្ម ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធទី៨នៃប្រកាសនេះ។

**ប្រការ ២៤.-**

វិញ្ញាបនបត្របញ្ជាក់បញ្ជិកាដីកសិកម្មដែលចេញដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មាន២(ពីរ)ប្រភេទ៖

១-**បញ្ជិកាពេញលេញ** ត្រូវបានផ្តល់ក្នុងករណីដែលអ្នកស្នើសុំការចុះបញ្ជីបានបំពេញតាមគ្រប់ការតម្រូវបមាណីយស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម និងនីតិវិធីនៃប្រកាសនេះ។ វិញ្ញាបនបត្របញ្ជាក់បញ្ជិកាពេញលេញនៃដីកសិកម្មមានសុពលភាព៣(បី)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកានោះ។

២-**បញ្ជិកាបណ្តោះអាសន្ន**ក្នុងករណីដែលអ្នកស្នើសុំការចុះបញ្ជីលើកដំបូងពុំទាន់មានទិន្នន័យពេញលេញឬមិនច្បាស់លាស់ អ្នកស្នើសុំត្រូវភ្ជាប់ទៅនឹងលក្ខខណ្ឌដោយត្រូវផ្តល់នូវព័ត៌មាននិងបំពេញលក្ខខណ្ឌចាំបាច់បន្ថែមផ្សេងទៀតជាក្រោយស្របតាមការតម្រូវបមាណីយ ជាពិសេសព័ត៌មានពាក់ព័ន្ធជីវប្រសិទ្ធភាពនៃប្រភេទដីកសិកម្មនោះ។ វិញ្ញាបនបត្របញ្ជាក់បញ្ជិកាបណ្តោះអាសន្ននៃដីកសិកម្មមានសុពលភាព១(មួយ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកានោះ។

ក្នុងរយៈពេល១(មួយ)ឆ្នាំគិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្របញ្ជិកាបណ្តោះអាសន្នអាចផ្ទេរទៅជាបញ្ជិកាពេញលេញនៅពេលដែលអ្នកស្នើសុំបានបំពេញតាមការតម្រូវបមាណីយគ្រប់គ្រាន់ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនិងនីតិវិធីនៃប្រកាសនេះ។

គំរូវិញ្ញាបនបត្របញ្ជាក់បញ្ជិកាជីកសិកម្ម ត្រូវបានកំណត់នៅក្នុងឧបសម្ពន្ធទី៩នៃប្រកាសនេះ។

**ប្រការ ២៥.-**

ក្នុងរយៈពេល៣(បី)ខែមុនកាលបរិច្ឆេទផុតសុពលភាពនៃបញ្ជិកាពេញលេញឬបញ្ជិកាបណ្តោះអាសន្ន បុគ្គលដែលទទួលសិទ្ធិលើការចុះបញ្ជីត្រូវស្នើសុំការចុះបញ្ជីជាថ្មីលើផលិតផលរបស់ខ្លួន។

ក្នុងករណីគ្មានសំណើសុំការចុះបញ្ជីជាថ្មី បញ្ជិកាពេញលេញឬបញ្ជិកាបណ្តោះអាសន្ននៃប្រភេទជីកសិកម្មនោះត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិនៅកាលបរិច្ឆេទផុតសុពលភាពដូចបានកំណត់នៅលើវិញ្ញាបនបត្របញ្ជាក់បញ្ជិកានោះ។

**ប្រការ ២៦.-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអនុញ្ញាតបន្តសុពលភាពបញ្ជិកាបណ្តោះអាសន្នជីកសិកម្មតែមួយលើកគត់ក្នុងរយៈពេល១២(ដប់ពីរ)ខែ។ នៅកាលបរិច្ឆេទផុតសុពលភាពបន្តក្នុងករណីអ្នកស្នើសុំនៅតែមិនអាចបំពេញគ្រប់គ្រាន់តាមការតម្រូវបមាណីយ បញ្ជិកាបណ្តោះអាសន្ននោះត្រូវនិរាករណ៍ដោយស្វ័យប្រវត្តិ។

បុគ្គលដែលកាន់កាប់បញ្ជិកាបណ្តោះអាសន្នជីកសិកម្មមិនអាចធ្វើប្រតិបត្តិការពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ ប៉ុន្តែអ្នកកាន់កាប់បញ្ជិកាបណ្តោះអាសន្នអាចធ្វើការសាកល្បងលើទីវាលពិសោធន៍បន្ថែមទៀតលើប្រភេទជីកសិកម្មនោះ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

**ប្រការ ២៧.-**

រាល់ផលិតផលជីកសិកម្មដែលខកខានក្នុងការស្នើសុំការចុះបញ្ជីជាថ្មីនៅមុនកាលបរិច្ឆេទផុតសុពលភាព ត្រូវចាត់ទុកជាផលិតផលជីកសិកម្មថ្មី ដែលសំណើសុំការចុះបញ្ជីត្រូវពិនិត្យវាយតម្លៃស្របតាមនីតិវិធីដូចមានចែងក្នុងប្រកាសនេះ។

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីជាថ្មីជីកសិកម្ម ត្រូវបង់កម្រៃសេវាកម្មជាមុនចូលថវិកាជាតិសម្រាប់ការចុះបញ្ជីជាថ្មី ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម។

**ប្រការ ២៨.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីជាថ្មីនូវជីកសិកម្មគ្រប់ប្រភេទ ត្រូវអនុវត្តលក្ខខណ្ឌដូចខាងក្រោម៖

១- ក្នុងករណីមានការផ្លាស់ប្តូរទិន្នន័យណាមួយដែលបានអះអាងនៅពេលសុំការចុះបញ្ជី

១៥/៣៥

លើកមុន ត្រូវផ្តល់ព័ត៌មាននិងទិន្នន័យបន្ថែមដោយភ្ជាប់មកជាមួយសំណុំបែបបទស្នើសុំការចុះបញ្ជីជាថ្មី។

២- ផ្តល់លទ្ធផលវិភាគចុងក្រោយបំផុតលើសមាសធាតុនៃប្រភេទជីកសិកម្មដែលស្នើសុំការចុះបញ្ជីជាថ្មី ដែលចេញដោយមន្ទីរពិសោធន៍ជាតិកសិកម្ម ឬមន្ទីរពិសោធន៍ដែលមានការទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ២៩.-**

ការផ្ទេរសិទ្ធិលើបញ្ជិកាជីកសិកម្មអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការសម្រេចពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយអ្នកស្នើសុំត្រូវអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោម៖

១- ក្នុងករណីបញ្ជិកាដើមដែលស្នើសុំផ្ទេរសិទ្ធិនៅមានសុពលភាពតែក្នុងរយៈពេល ៣(បី)ខែ ការផ្ទេរសិទ្ធិត្រូវប្រព្រឹត្តទៅក្រោមការស្នើសុំការចុះបញ្ជីជាថ្មីក្រោមបន្ទុករបស់អ្នកកាន់កាប់បញ្ជិកាដើម។

២- ត្រូវផ្តល់ព័ត៌មានអំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ថ្មី។

៣- ត្រូវបង់កម្រៃសេវាកម្មចូលថវិកាជាតិលើការចុះបញ្ជីជាថ្មី។

៤- ត្រូវធានាបមាណីយធានានៃសមាសធាតុជីកសិកម្មតាមការអះអាងក្នុងបញ្ជិកាដើមដែលត្រូវផ្ទេរសិទ្ធិ។

៥- ត្រូវទទួលខុសត្រូវលើរាល់កាតព្វកិច្ចពាក់ព័ន្ធក្នុងការកាន់កាប់បញ្ជិកាជីកសិកម្ម។

**ប្រការ ៣០.-**

នាយកដ្ឋាននីតិកម្មកសិកម្មត្រូវធ្វើសម្រង់បញ្ជីជីកសិកម្ម ដែលបានផ្តល់ការចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវតាមដានធ្វើបច្ចុប្បន្នភាពការចុះបញ្ជីជីកសិកម្មរៀងរាល់ឆ្នាំ ដើម្បីធ្វើអធិការកិច្ចលើចរាចរណ៍ទីផ្សារ និងជំរុញការអនុវត្តច្បាប់។

ត្រូវបានបញ្ឈប់រាល់ការធ្វើពាណិជ្ជកម្មនិងចរាចរណ៍លើទីផ្សារនូវជីកសិកម្មទាំងឡាយដែលមិនបានស្នើសុំការចុះបញ្ជីជាថ្មី ឬប្រើបញ្ជិកាផុតសុពលភាព ហើយត្រូវប្រមូលមកវិញក្រោមបន្ទុកសិទ្ធិវន្តលើបញ្ជិកានោះក្នុងរយៈពេល៦(ប្រាំមួយ)ខែ គិតចាប់ពីកាលបរិច្ឆេទផុតសុពលភាពបញ្ជិកា។

## ជំពូកទី ៧
## ការការពារសិទ្ធិលើទិន្នន័យ

**ប្រការ ៣១.-**

បន្ថែមលើការតម្រូវធ្វើវិភាគនិងការសាកល្បងជីវប្រសិទ្ធភាពលើទីវាលពិសោធន៍ ដោយអនុលោមតាមបទប្បញ្ញត្តិនិងនីតិវិធីនៃច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម រូបវន្តបុគ្គលឬនីតិបុគ្គល

១៥/៣៥

ដែលស្នើសុំការចុះបញ្ជីដីកសិកម្ម អាចស្នើសុំធ្វើការសាកល្បងលើទីវាលពិសោធន៍ជាក់លាក់បន្ថែម ដោយអនុវត្តចំពោះប្រភេទដំណាំឬក្រុមប្រភេទដំណាំ នៅតំបន់សាកល្បងផ្សេងៗគ្នា ដើម្បីបង្កើតទិន្នន័យជីវប្រសិទ្ធភាពថ្មីបន្ថែមនៃប្រភេទដីកសិកម្មនោះ។

**ប្រការ ៣២.-**

រាល់ទិន្នន័យជីវប្រសិទ្ធភាពថ្មីនៃដីកសិកម្មដែលបានសាកល្បងលើទីវាលពិសោធន៍សម្រាប់ស្នើសុំការចុះបញ្ជីដីកសិកម្មនោះនៅគ្រាដំបូងត្រូវបានផ្តល់ការការពារសិទ្ធិលើទិន្នន័យសាកល្បងជីវប្រសិទ្ធភាពនោះក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកា តាមការស្នើសុំរបស់អ្នកស្នើសុំការចុះបញ្ជី។

**ប្រការ ៣៣.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំការចុះបញ្ជីប្រភេទដីកសិកម្មដូចគ្នា និងមានប្រភពដើមលាយផ្សំដូចគ្នា អាចស្នើសុំការអនុញ្ញាតពីភាគីដែលកាន់កាប់សិទ្ធិលើបញ្ជិកានិងសិទ្ធិលើទិន្នន័យសាកល្បងជីវប្រសិទ្ធភាពថ្មី ដើម្បីប្រើប្រាស់ទិន្នន័យជីវប្រសិទ្ធភាពថ្មីនោះសម្រាប់ការចុះបញ្ជីដីកសិកម្មរបស់ខ្លួន។ ក្នុងករណីគ្មានការអនុញ្ញាតពីភាគីដែលកាន់កាប់សិទ្ធិលើទិន្នន័យ រូបវន្តបុគ្គលឬនីតិបុគ្គលនោះត្រូវប្រើប្រាស់ទិន្នន័យសាកល្បងជីវប្រសិទ្ធភាពថ្មីរបស់ខ្លួនដែលស្នើសុំបង្កើតស្របតាមនីតិវិធីនៃប្រកាសនេះ ឬត្រូវប្រើទិន្នន័យសាកល្បងជីវប្រសិទ្ធភាពតាមការតម្រូវដែលចេញដោយស្ថានីយពិសោធន៍នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬដោយអ្នកស្រាវជ្រាវ ដែលទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ផុតរយៈពេល៥(ប្រាំ)ឆ្នាំគិតចាប់ពីកាលបរិច្ឆេទចេញវិញ្ញាបនបត្របញ្ជាក់បញ្ជិកា រាល់ទិន្នន័យជីវប្រសិទ្ធភាពដែលពាក់ព័ន្ធ អាចប្រើប្រាស់ជំនួសក្នុងការស្នើសុំការចុះបញ្ជីដីកសិកម្មដែលមានប្រភេទដូចគ្នា និងមានប្រភពដើមលាយផ្សំដូចគ្នា។

## ជំពូកទី ៨
## ការចុះបញ្ជីដីកសិកម្ម
## សម្រាប់តម្រូវការក្រៅគោលបំណងពាណិជ្ជកម្ម

**ប្រការ ៣៤.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលស្នើសុំនាំចូលដីកសិកម្មសម្រាប់តម្រូវការប្រើប្រាស់ក្រៅគោលបំណងពាណិជ្ជកម្មរួមមានតម្រូវការសាធារណៈក្នុងវិស័យសិក្សាធិការ ការស្រាវជ្រាវ វិស័យសុខាភិបាល ការធ្វើដល់សាធារណៈ ការតាំងពិព័រណ៍ផ្លូវការ ឬសម្រាប់តម្រូវការប្រើប្រាស់ចុងក្រោយផ្សេងទៀត

១៦/៣៥

ដែលមិនមែនជាការធ្វើពាណិជ្ជកម្មឬចរាចរណ៍លើទីផ្សារ ត្រូវស្នើសុំការចុះបញ្ជីនិងលិខិតអនុញ្ញាតនាំចូលនៅនាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ ៣៥.-**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចអនុគ្រោះការតម្រូវបមាណីយចំពោះសំណើសុំការចុះបញ្ជីជីកសិកម្មសម្រាប់តម្រូវការក្រៅគោលបំណងពាណិជ្ជកម្ម ប៉ុន្តែចាំបាច់ត្រូវផ្តល់ឯកសារប្រភពដើមស្តីពីអត្តសញ្ញាណយថាប្រភេទនៃជីកសិកម្មនោះ រួមមានៈ

- ប្រភេទជីកសិកម្មនិងឈ្មោះពាណិជ្ជកម្ម
- សារធាតុចិញ្ចឹមនៃប្រភេទជីកសិកម្ម
- ឈ្មោះប្រទេស ក្រុមហ៊ុនប្រភពដើមផលិតឬនាំចូលមកកម្ពុជា
- មុខសញ្ញាប្រើប្រាស់និងបរិមាណប្រើប្រាស់ដែលត្រូវស្នើសុំនាំចូល។

ក្នុងករណីដូចមានចែងក្នុងកថាខណ្ឌទី១នៃប្រការនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាចផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាបណ្តោះអាសន្នប្រភេទជីកសិកម្មនោះសម្រាប់តែតម្រូវការប្រើប្រាស់ជាក់លាក់ក្នុងសុពលភាពរយៈពេល១(មួយ)ឆ្នាំប៉ុណ្ណោះ។

**ប្រការ ៣៦.-**

ជីកសិកម្មដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាពេញលេញឬបញ្ជិកាបណ្តោះអាសន្ន និងបានអនុញ្ញាតឲ្យនាំចូលសម្រាប់តម្រូវការក្រៅគោលបំណងពាណិជ្ជកម្ម មិនអាចធ្វើចរាចរណ៍លើទីផ្សារឬធ្វើការផ្គត់ផ្គង់ចែកចាយជាលក្ខណៈពាណិជ្ជកម្ម និងធ្វើការផ្សាយពាណិជ្ជកម្មបានឡើយ។

ការប្រព្រឹត្តល្មើសនឹងប្រការនេះ ត្រូវផ្តន្ទាទោសដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន។

## ជំពូកទី ៩
## ទោសប្បញ្ញត្តិ

**ប្រការ ៣៧.-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រព្រឹត្តល្មើសឬមិនគោរពតាមនីតិវិធីនិងបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មជាក់លាក់ដោយអនុលោមតាមទោសប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មជាធរមាន។

១៧/៣៥

# ជំពូកទី ១០
# អវសានប្បញ្ញត្តិ

**ប្រការ ៣៨.-**

ប្រកាសឬសេចក្ដីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣៩.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១២

**រដ្ឋមន្ត្រី**

ចាន់ សារុន

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-ក្រសួងយុត្តិធម៌
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
-សាលារាជធានី ខេត្ត
-ដូចប្រការ ៣៩
-ឯកសារ កាលប្បវត្តិ

១៧/៣៥